CITY OF
LONG BEACH

# សម្រាប់ឆ្នាំសារពើពន្ធ 2023 ថវិកាដែលបានស្នើ

សេចក្តីសង្ខេបថវិកាសហគមន៍



# ការត្រួតពិនិត្យលើការប្រើប្រាស់ថវិកា
## ឆ្នាំសារពើពន្ធ ២០២២

ច្បាប់ស្តារទីក្រុងឡុងប៊ិចឡើងវិញ
**$271.3 លានដុល្លារ**

បានរចនា ឬអនុវត្តនូវកម្មវិធីស្តារឡើងវិញ **ជាង 80+**

**ជាង $8 លានដុល្លារ បានផ្តល់ដល់** អាជីវកម្មក្នុងស្រុក និងអង្គការមិនរកប្រាក់ចំណេញចំនួន **700**

**$44.5 លានដុល្លារ** ផ្តល់ជំនួយក្នុងការជួលទៅដល់ប្រជាពលរដ្ឋ ជិត **6,100 នាក់**

ចាប់តាំងពីឆ្នាំ **2020** មក, **បានបញ្ចប់ច្រើនជាង 880 យូនីត ដែលមានតម្លៃសមរម្យ, ដែលកំពុងតែសាងសង់ ឬត្រូវបានស្នើឡើងនៅទូ**ទាំងទីក្រុង

**បន្ត និងពង្រីកកម្មវិធី PROJECT ROOMKEY PROGRAM,** ដោយបន្ថែមបន្ទប់ចំនួន **26** និងបន្ទប់សរុបគឺមាន **274**

**បានយកចេញនូវរូបគំនូរក្រវែមក្រវ៉ាម ចំនួន 1.25 លានហ្វីតការ៉េ**

**បានបន្ថែមគ្រែដែលជាជម្រកចំនួន 552 គ្រែ ក្នុងរយៈពេល 2 ឆ្នាំកន្លងមកនេះ** ដែលបណ្តាលឱ្យសមត្ថភាពសរុប ឈានដល់ **994** គ្រែ

**បានយកចេញនូវសំរាមជាង 2,100 តោន និងទំនិញដែលបោះចោលដោយខុសច្បាប់នៅតាមផ្លូវសាធារណៈ** ផ្លូវលំក្រោយផ្ទះ និងច្រករបៀងអាជីវកម្មដែលមានចរាចរណ៍ខ្ពស់

ការទៅសួរសុខទុក្ខជំរំបោះតង់របស់ជនអនាថា ជាង **1,000** កន្លែង, ដែលនេះបានធ្វើការផ្សព្វផ្សាយ ទៅកាន់មនុស្ស **1,800** ដែលកំពុងជួបប្រទះភាពគ្មានផ្ទះសម្បែង

**បានចាក់បំពេញផ្លូវក្រហេងក្រហូង ជាង 40,000 កន្លែង**

**រឹបអូសបានអាវុធ 112 ដើម** និងបានចាប់ខ្លួនមនុស្សចំនួន **98** នាក់ ដែលពាក់ព័ន្ធនឹងអាវុធ

**ឆ្លើយតបទៅនឹងអគ្គីភ័យជាង 76,000 ដង, សុវត្ថិភាពសមុទ្រ និងឧប្បត្តិហេតុសង្គ្រោះបន្ទាន់ផ្សេងទៀត**

**មជ្ឈមណ្ឌលជួយបម្រុងទុក 9-1-1 បានបង្កើត**ឡើងដោយមានស្ថានីយ៍ការងារ **14** កន្លែង

ចាប់ផ្តើមកម្មវិធីក្រុមប្រឹក្សាសំរាប់ផ្តល់ការ**ប្រឹក្សាយុវជន ចំនួន 11 រូប**

ធ្វើតាមផែនការ ដើម្បីអនុវត្តផែនការ**សម្របខ្លួនទៅនឹងសកម្មភាពអាកាសធាតុជាលើកដំបូង**

**បានបញ្ចប់នូវបន្ទប់ទទួលភ្ញៀវលក់សំបុត្រថ្មីរបស់ព្រលានយន្តហោះ** និងប្រព័ន្ធត្រួតពិនិត្យឥវ៉ាន់

បានចែកចាយដល់ឪពុកម្តាយនូវឧបករណ៍អភិវឌ្ឍន៍អក្ខរកម្មដំបូងជាង **2,000**

# សារពីអ្នកគ្រប់គ្រងទីក្រុង

ខ្ញុំមានសេចក្តីរីករាយក្នុងការបង្ហាញជូនអ្នក នូវថវិកាឆ្នាំសារពើពន្ធ 2023 (ឆ្នាំសារពើពន្ធ FY 23) ដែលបានស្នើ។ ថវិកានេះត្រូវបានបង្កើតឡើង ក្នុងអំឡុងពេលនៃការផ្លាស់ប្តូរដ៏សំខាន់មួយ។ ខណៈពេលដែលទីក្រុងឡុងប៊ិច (ទីក្រុង) បន្តរសះស្បើយពីផលប៉ះពាល់យូរអង្វែង ដោយសារការរាតត្បាតនៃជំងឺ COVID-19, ទីក្រុង នៅតែបន្តការប្តេជ្ញាចិត្តក្នុងការផ្តល់សេវាសាធារណៈសំខាន់ៗ ផ្តល់អាទិភាពដល់ការស្តារឡើងវិញនូវការគាំទ្រចំពោះប្រជាពលរដ្ឋ និងអាជីវកម្ម និងធ្វើឱ្យការវិនិយោគដ៏រឹងមាំចំពោះ ហេដ្ឋារចនាសម្ព័ន្ធរបស់ទីក្រុង។

ខ្ញុំមានមោទនភាពជាខ្លាំង ចំពោះអ្វីៗទាំងអស់ដែលទីក្រុងសម្រេចបានក្នុងអំឡុងពេលដ៏លំបាកនេះ ហើយនៅពេលយើងសម្លឹងឆ្ពោះទៅមុខទៅរកឆ្នាំសារពើពន្ធ 23, ខ្ញុំនៅតែបន្តប្តេជ្ញាចិត្តយ៉ាងពេញទំហឹង ក្នុងការបង្កើតនូវ ថវិកាទីក្រុង ដែលឆ្លើយតបទៅនឹងតម្រូវការដែលតែងតែមានផ្លាស់ប្តូរជានិច្ចរបស់សហគមន៍របស់យើង។ នៅទីបញ្ចប់ ថវិកាឆ្នាំសារពើពន្ធ FY 23 ដែលបានស្នើឡើង បណ្តាលឱ្យមានការវិនិយោគយ៉ាងច្រើនទៅក្នុងវិស័យនានាជាច្រើន ដោយមិនបន្ថែមថវិការទៅលើកង្វះខាតនៃរចនាសម្ព័ន្ធមូលនិធិទូទៅឡើយ។

វិស័យអាទិភាពទាំងនេះ រួមមានខាងក្រោម៖

**ដោះស្រាយភាពគ្មានផ្ទះសម្បែង**

**សុវត្ថិភាពសហគមន៍**

**សមធម៌, ការដាក់រួមបញ្ចូល, សុខភាព និងគុណភាពនៃការគាំទ្រជីវិត**

**ការទាក់ទាញអាជីវកម្ម, ការគាំទ្រ, និងការអភិវឌ្ឍន៍សេដ្ឋកិច្ច**

**សិល្បៈ, វប្បធម៌, និងទេសចរណ៍**

**ហេដ្ឋារចនាសម្ព័ន្ធ ការថែទាំ និងការវិនិយោគដែលត្រូវការជាចាំបាច់**

**ការប្រែប្រួលអាកាសធាតុ និងនិរន្តរភាពបរិស្ថាន**

**ការជ្រើសរើសបុគ្គលិក, ការរក្សាទុក, និងការពង្រឹងសេវារដ្ឋបាលផ្ទៃក្នុង**

**តម្រូវការប្រតិបត្តិការដែលមិនត្រូវផ្តល់ការមូលនិធិ និងការកែលម្អបំណុលសំខាន់ៗ**

ការវិនិយោគទាំងនេះ បានយកមកពិចារណា នៃអាទិភាពរបស់ក្រុមប្រឹក្សាក្រុង និងមតិយោបល់នានារបស់សហគមន៍ដែលត្រូវបានទទួលពីអ្នកប្រជាពលរដ្ឋ នៅដំណាក់កាលដំបូងនៃដំណើរការអភិវឌ្ឍន៍ថវិកា។ សៀវភៅថវិកាសហគមន៍នេះផ្តល់នូវចំណុចសំខាន់ៗមួយចំនួន ដែលមានព័ត៌មានដ៏ទូលំទូលាយ និងលម្អិតបន្ថែមទៀត ដែលមាននៅក្នុងសៀវភៅថវិកាពេញលេញ នៅលើអ៊ីនធឺណិត។ ថវិកាប្រចាំឆ្នាំរបស់ទីក្រុង គឺជាឯកសារគោលនយោបាយដ៏សំខាន់បំផុតមួយ ដែលទីក្រុងបានបង្កើតឡើង, ដូច្នេះហើយ យើងសូមអរគុណចំពោះការចាប់អារម្មណ៍របស់អ្នកចំពោះថវិកាឆ្នាំសារពើពន្ធ FY 23 ហើយខ្ញុំទន្ទឹងរង់ចាំស្តាប់យោបល់ពីអ្នក ក្នុងខណៈ ពេលយើងធ្វើការដើម្បីបញ្ចប់ថវិកា។ ខ្ញុំនៅតែមានទំនុកចិត្ត និងសង្ឃឹមថា ពួកយើងទាំងអស់គ្នា នឹងបន្តកសាងទីក្រុងឡុងប៊ិច ដែលមានសុវត្ថិភាព ថាមវន្ត/ការរីវត្តវិជ្ជមាន និងភាពរីកចម្រើន។

**Thomas B. Modica**
City Manager

# ចំណុចសំខាន់នៃថវិកាឆ្នាំសារពើពន្ធ FY 23 ដែលបានស្នើឡើង

សម្រាប់បញ្ជីទូលំទូលាយ, សូមមើលសៀវភៅថវិកាពេញលេញដែលមាននៅលើគេហទំព័រ LONGBEACH.GOV/FINANCE

## ដោះស្រាយជនអនាថា/ជនគ្មានផ្ទះសម្បែង

ការស្វែងរកដំណោះស្រាយចំពោះវិបត្តិជនគ្មានផ្ទះសម្បែង នៅតែបន្តជាអាទិភាពចម្បងសម្រាប់ទីក្រុងឡុងបិច ដោយប្រើប្រាស់បណ្តាញនៃការផ្តល់មូលនិធិដែលផ្តល់ផលប្រយោជន៍អតិបរិមារបស់ទីក្រុង, ខោនធីជាច្រើន, រដ្ឋ, និងសហព័ន្ធ។ ថវិកាគាំទ្រសេវាកម្មដែលមានស្រាប់ និផ្តល់ជាអនុសាសន៍ងណែនាំអោយធ្វើការកែលម្អ, រួមទាំង៖

- បន្ថែមការចូលរួមការស្តារឡើងវិញលើកទី 3 ដើម្បីសម្រេចបាននូវក្រុមសុខភាពសមូហភាព (REACH) ដែលផ្តល់សេវាកម្មបន្ថែមម៉ោងបន្ទាប់ពីចប់ការងារ និងចុងសប្តាហ៍។
- បន្ថែមមុខតំណែងទីប្រឹក្សាពីររូប ដែលនឹងសម្របសម្រួលជាមួយមជ្ឈមណ្ឌលទូរស័ព្ទរបស់ទីក្រុង ដើម្បីបង្កើនទំនាក់ទំនងជាមួយសមាជិកសហគមន៍ និងឆ្លើយតបដល់អ្នកដែលស្វែងរកជំនួយ។
- ប្រើប្រាស់មូលនិធិវិធានការណ៍ Measure A ម្តង ចំនួន $2.1 លានដុល្លារ សម្រាប់ការផ្សព្វផ្សាយរយៈពេល 2 ឆ្នាំ និងការផ្តួចផ្តើមការសម្អាតនៅតាមដងទន្លេ។

## សុវត្ថិភាពសហគមន៍

ទីក្រុងបានប្តេជ្ញាចិត្តក្នុងការផ្តល់នូវសហគមន៍ប្រកបដោយសុវត្ថិភាព សម្រាប់ប្រជាពលរដ្ឋទីក្រុងឡុងបិចទាំងអស់ ហើយបន្តស្វែងរកការច្នៃប្រឌិត និងវិធីសាស្រ្តសហការ ដើម្បីសម្រេចបានគោលដៅនេះ។ ធាតុថ្មីដែលបានស្នើឡើងក្នុងថវិកា រួមមាន:

- មូលនិធិតែម្តង ចំនួន $980,000 ដុល្លារ សម្រាប់កម្មវិធីឆ្លើយតបវិបត្តិសហគមន៍ ដែលក្រុមអ្នកឆ្លើយតបដំបូងដែលគ្មានអាវុធអាចឆ្លើយតបចំពោះសុខភាពផ្លូវចិត្ត, ការរំលោភបំពានសារធាតុញៀន, និងគុណភាពនៃជីវិត ដែលពាក់ព័ន្ធទៅនឹងការទូរស័ព្ទទៅកាន់ 9-1-1។
- បង្កើតការិយាល័យការឆ្លើយតប និងការចូលរួមសហការ (CRE) ថ្មីមួយនៅក្នុងនាយកដ្ឋានប៉ូលីស ដើម្បីជួយសម្រួលដល់វិធីសាស្រ្តប្រកបដោយភាពច្នៃប្រឌិតដែលផ្តោតលើការកសាងទំនាក់ទំនងសហគមន៍ប្រកបដោយអត្ថន័យ និងបន្ថែមមន្ត្រីប៉ូលីសថ្មីចំនួន 20 នាក់ (មន្ត្រីកង់ 16 នាក់ និងមន្ត្រីគុណភាពជីវិត 4 នាក់) ដើម្បីដោះស្រាយបញ្ហាឫសគល់នៃឧក្រិដ្ឋកម្មតាមរយៈម៉ូដែលនៃការយាមកាមសហគមន៍ដោយផ្អែកលើទំនាក់ទំនង។

## សមធម៌, ការដាក់រួមបញ្ចូល, សុខភាព, និងគុណភាពនៃការគាំទ្រជីវិត

ទីក្រុងបានប្តេជ្ញាចិត្តក្នុងការលើកកម្ពស់ឱកាសសម្រាប់សុខភាពល្អបំផុត, សន្តិសុខហិរញ្ញវត្ថុ, និងគុណភាពជីវិតទាំងមូល សម្រាប់ប្រជាពលរដ្ឋ នៅក្នុងទូទាំងទីក្រុង។ ថវិកាធ្វើឱ្យមានការវិនិយោគបន្ថែម ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដែលកំពុងបន្តក្នុងការជំរុញឱ្យទីក្រុងឡុងបិច កាន់តែមានការរួមបញ្ចូល និងសមធម៌ រួមទាំង៖

- ផ្តល់មូលនិធិយ៉ាងពេញលេញនូវមុខតំណែងដែលនឹងផ្តល់ការគាំទ្រដល់គណៈកម្មការស្ត្រី និងកុមារី, គណៈកម្មការសមធម៌ និងទំនាក់ទំនងមនុស្ស, មូលនិធិយុត្តិធម៌, និងការគាំទ្រសម្រាប់កិច្ចខិតខំប្រឹងប្រែងសមធម៌ពូជសាសន៍ និងការផ្សះផ្សាជាតិសាសន៍ដែលកំពុងបន្ត។
- បង្កើនមូលនិធិរចនាសម្ព័ន្ធចំនួន $20,000 ដុល្លារ សម្រាប់ការបង្កើនសេវាបកប្រែសរសេរ និងបកប្រែផ្ទាល់មាត់។
- មូលនិធិវិធានការណ៍ Measure US ម្តង នៃថវិការចំនួន $511,620 ដុល្លារសម្រាប់ជំនួយ និងថវិការ/គ្រឿងលើកទឹកចិត្តផ្អែកលើសហគមន៍ជុំវិញការអភិវឌ្ឍន៍យុវជន។
- បង្កើនមូលនិធិរចនាសម្ព័ន្ធចំនួន $400,000 ដុល្លារ និងបន្ថែមមូលនិធិម្តងចំនួន $400,000 ដុល្លារ ដើម្បីបង្កើនថវិកាសម្ភារៈរបស់បណ្ណាល័យ ដោយគាំទ្រដល់ការប្រមូលសម្ភារៈ/សៀវភៅដាក់ក្នុងបណ្ណាល័យរួម និងចម្រុះ។

## សមធម៌, ការដាក់រួមបញ្ចូល, សុខភាព, និងគុណភាពនៃការគាំទ្រជីវិត

ការគាំទ្រដល់អាជីវកម្មឡុងបិច និងការលើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច គឺជាផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្រ្តរបស់ទីក្រុង ក្នុងការបង្កើនមូលដ្ឋានប្រាក់ចំណូលរបស់ខ្លួន និងបន្តឆ្ពោះទៅរកចក្ខុវិស័យនៃការក្លាយជាទីក្រុងនៃឱកាស។ ថវិកាស្នើសុំការវិនិយោគថ្មី ដើម្បីគាំទ្រដល់សហគមន៍អាជីវកម្ម រួមមានៈ

- បន្ថែមមុខតំណែងអ្នកវិភាគ ដើម្បីបម្រើជាទំនាក់ទំនងអាជីវកម្ម និងគាំទ្រកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយពាណិជ្ជកម្ម។
- បន្ថែមមុខតំណែងជំនួយការផ្តល់ប័ណ្ណអនុញ្ញាតិចំនួនបីមុខតំណែង ដើម្បីធានាអោយមានបុគ្គលិកគ្រប់គ្រាន់ នៅឯមជ្ឈមណ្ឌលផ្តល់ប័ណ្ណអនុញ្ញាត។
- បន្ថែមមុខតំណែងអ្នករៀបចំផែនការចំនួនពីរមុខតំណែងដល់បុគ្គលិកផ្នែកបញ្ជរសាធារណៈ និងខ្សែទូរស័ព្ទបែងចែកតំបន់ ដើម្បីគាំទ្រដល់ការពិនិត្យមើលផែនការ និងសេវាកម្មអតិថិជន។

# ចំណុចសំខាន់នៃថវិកាឆ្នាំសារពើពន្ធ FY 23 ដែលបានស្នើឡើង

**សិល្បៈ, វប្បធម៌, និងទេសចរណ៍**

ទីក្រុងមានប្រវត្តិដ៏រឹងមាំក្នុងការគាំទ្រការលើកកម្ពស់សិល្បៈ, វប្បធម៌, និងទេសចរណ៍, ហើយថវិកាឆ្នាំសារពើពន្ធ FY 23 កំពុងរក្សានូវការវិនិយោគជាយុទ្ធសាស្ត្ររបស់ខ្លួននៅក្នុងវិស័យនេះ ដែលភាគច្រើនគាំទ្រដោយមូលនិធិផ្សព្វផ្សាយ និងផ្សព្វផ្សាយពិសេស (SAP)។ លើសពីនេះ ថវិកាស្នើនូវធាតុនៅក្នុងមូលនិធិដែលមិនមែនជា SAP ដើម្បីគាំទ្របន្ថែមទៀត រួមទាំង៖

- បង្កើតការិយាល័យកំពង់ផែ Pier H ថ្មី ដើម្បីត្រួតពិនិត្យប្រតិបត្តិការរបស់កប៉ាល់ Queen Mary និងការអភិវឌ្ឍន៍តំបន់ជុំវិញនោះ។
- បន្ថែមអ្នកសម្របសម្រួលព្រឹត្តិការណ៍ ដើម្បីជួយដល់ការបើកដំណើរការឡើងវិញនៃកប៉ាល់ Queen Mary។
- បន្ថែមមុខតំណែងអ្នកវិភាគ សម្រាប់ការត្រួតពិនិត្យនៃការធ្វើអោយប្រសើរឡើងនៃកិច្ចសន្យាប្រតិបត្តិការ សម្រាប់មជ្ឈមណ្ឌលសន្និបាតក្រុងឡុងប៊ិច។

**ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ, ការថែទាំ, និងតម្រូវការសំខាន់ៗ**

ការវិនិយោគ និងការផ្តល់អាទិភាពលើតម្រូវការហេដ្ឋារចនាសម្ព័ន្ធ និងការថែទាំនៅតែជាផ្នែកសំខាន់នៃកិច្ចខិតខំប្រឹងប្រែងរបស់ទីក្រុង ក្នុងការបង្កើនធនធានបច្ចុប្បន្នសម្រាប់អត្ថប្រយោជន៍ជាបន្តបន្ទាប់ រួមទាំង៖

- កម្មវិធីកែលម្អទុនឆ្នាំសារពើពន្ធ FY 23 របស់ទីក្រុង គឺមាន $177 លានដុល្លារ ដោយមិនរាប់បញ្ចូលនូវកំពង់ផែ។
- ផែនការថ្មី $228 លានដុល្លារ, ផែនការ 5 ឆ្នាំសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ, រួមទាំង $150 លានដុល្លារ ពីការចេញមូលបត្របំណុលវិធានការណ៍ Measure A។
- វិធានការណ៍ Measure A ផ្តល់ថវិកាម្តង ចំនួន $1.8 លានដុល្លារ ដើម្បី យកចេញដើមឈើខូចទ្រង់ទ្រាយនៅក្នុងឧទ្យាន។

**ការប្រែប្រួលអាកាសធាតុ និងនិរន្តរភាពបរិស្ថាន**

ការគ្រប់គ្រងធនធានបរិស្ថានរបស់ទីក្រុង ការប្រយុទ្ធប្រឆាំងនឹងផលវិបាកនៃការប្រែប្រួលអាកាសធាតុ និងការគាំទ្រការអនុវត្តនិរន្តរភាពក្នុងតំបន់ផ្សេងៗ គឺជាអាទិភាពចម្បងសម្រាប់ទីក្រុង។ ការវិនិយោគសំខាន់ៗជាច្រើនដែលបានស្នើឡើងក្នុងថវិកាឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តនេះ រួមមានៈ

- បង្កើតការិយាល័យសកម្មភាពអាកាសធាតុថ្មីនៅក្នុងការិយាល័យអ្នកគ្រប់គ្រងទីក្រុង ដោយបន្ថែមមុខតំណែងថ្មីចំនួន 4 សម្រាប់មុខតំណែងសរុបចំនួន 9.3 នៅពេលរួមបញ្ចូលជាមួយការិយាល័យនិរន្តរភាពបច្ចុប្បន្ន។
- បន្ថែមមុខតំណែងអ្នករៀបចំផែនការ ដើម្បីជួយអនុវត្តសកម្មភាពផែនការសកម្មភាពអាកាសធាតុ និងផែនការសម្របខ្លួនរបស់ទីក្រុង។
- បែងចែកកម្មវិធី ជាង $7 លានដុល្លារនៅក្នុងកម្មវិធី AB 32 Cap-and-Trade ដែលគាំទ្រគម្រោងដែលអាចបង្ហាញពីការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ GHG មូលនិធិ 83% បានវិនិយោគក្នុងសហគមន៍ដែលជួបការលំបាក និង/ឬប្រាក់ចំណូលទាប។

**ការជ្រើសរើសបុគ្គលិក, ការរក្សាទុក, និងការពង្រឹងសេវាកម្មរដ្ឋបាលផ្ទៃក្នុង**

អង្គការនានានៅជុំវិញប្រទេស កំពុងប្រឈមមុខនឹងការលាលែងពីតំណែងដ៏ច្រើនក្រៃលែង ដែលជាបាតុភូតមួយដែលពិពណ៌នាអំពីចំនួនកំណត់ត្រានៃអ្នកចាកចេញពីការងាររបស់ពួកគេ បន្ទាប់ពីជំងឺរាតត្បាតរាតត្បាត។ ថវិកាឆ្នាំសារពើពន្ធ FY 23 រួមបញ្ចូលការវិនិយោគ ដើម្បីជួយទីក្រុងឡុងប៊ិច ដើម្បីគាំទ្រដល់ការជ្រើសរើសបុគ្គលិក និងកិច្ចខិតខំប្រឹងប្រែងរក្សាទុកដ៏រឹងមាំ រួមទាំង៖

- បន្ថែមមុខតំណែងអ្នកវិភាគបុគ្គលិកចំនួនពីររូប និងមុខតំណែងជំនួយការបុគ្គលិកម្នាក់នៅក្នុងនាយកដ្ឋានមុខងារស៊ីវិល ដើម្បីជួយកែលម្អពេលវេលាក្នុងការជួលបុគ្គលិក។
- បន្ថែមមុខតំណែងអ្នកវិភាគបុគ្គលិកម្នាក់ នៅក្នុងនាយកដ្ឋានធនធានមនុស្ស ដើម្បីផ្តោតលើការចំណាត់ថ្នាក់ និងសំណងបុគ្គលិក។
- បន្ថែមមូលនិធិរចនាសម្ព័ន្ធចំនួន $104,317 ដុល្លារ សម្រាប់ប្រព័ន្ធគ្រប់គ្រងការរៀនសូត្រ ក្នុងការអភិវឌ្ឍន៍ និងការបណ្តុះបណ្តាលបុគ្គលិកទូទាំងទីក្រុង។

**តម្រូវការប្រតិបត្តិការដែលមិនបានផ្តល់នូវមូលនិធិ និងការកែលម្អការទទួលខុសត្រូវសំខាន់ៗ**

ជាផ្នែកមួយនៃការធ្វើបច្ចុប្បន្នភាពថវិកាមូលដ្ឋានឆ្នាំសារពើពន្ធ FY 23 ទីក្រុងអាចដោះស្រាយ ឬធ្វើឱ្យមានការវិវឌ្ឍន៍ឆ្ពោះទៅរកការផ្តល់មូលនិធិ នៃបំណុលរយៈពេលខ្លី និងរយៈពេលវែង ដែលមិនមានការផ្តល់នូវមូលនិធិមួយចំនួនរបស់ទីក្រុង រួមទាំង $300,000 ដុល្លារ ដើម្បីអនុញ្ញាតឱ្យកាត់មេយធាងនៃដើមឈើតាមដងផ្លូវ ដែលស្ថិតនៅក្នុងការអនុវត្តការងារដែលមានវដ្តនៃរយៈពេល 6 ឆ្នាំ; ទឹកប្រាក់ចំនួន $617,467 ដុល្លារ ជួយដោះស្រាយទឹកតម្រូវការទឹកបន្ថែម ដើម្បីរក្សាកន្លែងអោយមានពណ៌បៃតង, មានសុវត្ថិភាព, និងមានសុខភាពល្អនៅកន្លែងសាធារណៈរបស់យើង, $465,000 ដុល្លារដើម្បីសម្រេចបាននូវកម្រិតនៃការកាត់បន្ថយស្មៅដោយប្រើថ្នាំសំលាប់ស្មៅជំនួសវិញ; និង $499,258 ដុល្លារ សម្រាប់ថ្លៃព្យាបាលដែលត្រូវការនៅក្នុងការិយាល័យសេវាកម្មថែទាំសត្វ និងកម្មវិធី Compassion Saves Program។

## សំឡឹងមើលអនាគត

ស្ថានភាពកង្វះមូលនិធិទូទៅនៃឆ្នាំសារពើពន្ធ FY 23 ប្រមាណ $20.2 លានដុល្លារ បូកនឹង $4.9 លានដុល្លារ នៃការប្រើប្រាស់មួយដងដែលត្រូវបានស្នើឡើង នឹងត្រូវបានដោះស្រាយជាបណ្តោះអាសន្នជាមួយនឹងដំណោះស្រាយម្តង រួមទាំងថវិកាដែលអាចរកបានតាមរយៈច្បាប់ស្តីពីការស្តារក្រុងឡុងប៊ិចឡើងវិញ និងទុនបម្រុងដែលបានកំណត់ពីមុន ដើម្បីកាត់បន្ថយផលប៉ះពាល់នៃវាស់វែងការចាញ់វិវាទ Measure M។ នេះគឺជាដំណោះស្រាយតែម្តង ហើយទីក្រុងនឹងត្រូវដោះស្រាយនូវកង្វះខាត នៅក្នុងឆ្នាំសារពើពន្ធ FY 24 ដែលបច្ចុប្បន្នត្រូវបានព្យាករណ៍ថា មានចំនួន $25.6 លានដុល្លារ។ អ្នកគ្រប់គ្រងទីក្រុង និងបុគ្គលិកនឹងបង្កើតផែនការដើម្បីរៀបចំតទល់បញ្ហាប្រឈមថវិកានាពេលអនាគត ហើយធ្វើការរួមគ្នាជាមួយអភិបាលក្រុង, ក្រុមប្រឹក្សាក្រុង, និងសហគមន៍ ដើម្បីផ្តល់សេវាកម្មល្អបំផុតជាមួយនឹងការអនុវត្តសារពើពន្ធប្រកបដោយការប្រុងប្រយ័ត្ន។

# ការយល់ដឹងអំពីមូលនិធិថវិការបស់ទីក្រុង

## ទីក្រុងមានមូលនិធិថវិកាចំនួន 36

មូលនិធិទូទៅដែលមានប្រហែល 21 ភាគរយនៃថវិកា (ប្រហែល $670 លានដុល្លារ) គឺជាមូលនិធិតែមួយគត់ដែលផ្អែកលើការសម្រេចចិត្តឆន្ទានុសិទ្ធទាំងស្រុង ហើយគាំទ្រសេវាកម្មភាគច្រើនដល់អ្នកផ្តល់សេវាកម្មជាមួយទីក្រុង ដូចជាការងារសាធារណៈ, សុវត្ថិភាពសាធារណៈ, សួនឧទ្យាន និងបណ្ណាល័យ ជាដើម។ មូលនិធិសាមសិបប្រាំផ្សេងទៀត បង្កើតបាននូវថវិការភាគច្រើននៃទីក្រុង ហើយត្រូវបានរឹតបន្តឹងដោយច្បាប់សម្រាប់សេវាកម្មជាក់លាក់។ ថវិកានេះ ស្ថិតក្នុងប្រភេទ ដូចខាងក្រោម៖

### មូលនិធិសហគ្រាស
### $1.2 ពាន់លានដុល្លារ

មូលនិធិទាំងនេះដំណើរការដូចជាការគិតថ្លៃអាជីវកម្ម សម្រាប់សេវាកម្មដូចជាព្រលានយន្តហោះ, កំពង់ផែ, និងទឹក។

### មូលនិធិដីក្បែរឆ្នេរ
### $236 លានដុល្លារ

មូលនិធិទាំងនេះគាំទ្រដល់ប្រតិបត្តិការ និងគម្រោងនៅតាមតំបន់ឆ្នេរ ដោយទទួលបានមូលនិធិពីប្រាក់ចំណូលពីប្រេង, ការផ្ទេរប្រាក់ពីកំពង់ផែ និងថ្លៃសេវាផែចតកប៉ាល់កំសាន្ត ក្នុងចំណោមប្រាក់ចំណូលផ្សេងៗទៀត។

### មូលនិធិសេវាបំណុល
### $35 លានដុល្លារ

មូលនិធិទាំងនេះសម្រាប់ការទូទាត់បំណុលរបស់រដ្ឋាភិបាល

### មូលនិធិចំណូលពិសេស
### $247 លានដុល្លារ

មូលនិធិទាំងនេះមានគណនីសម្រាប់សកម្មភាពដែលត្រូវបានបង់ដោយជំនួយរបស់រដ្ឋ, និងសហព័ន្ធ, ពន្ធ ឬប្រភពចំណូលដែលបានកំណត់ដែលត្រូវបានកម្រិតសម្រាប់គោលបំណងពិសេស ដូចជាមូលនិធិសុខភាព ជាដើម។

### មូលនិធិគម្រោងដើមទុន
### $180 លានដុល្លារ

មូលនិធិទាំងនេះមានសម្រាប់ការរៀបចំផែនការការរចនា និងការសាងសង់ការកែលម្អដើមទុនសំខាន់ៗ។ ផ្តល់មូលនិធិដោយជំនួយរបស់សហព័ន្ធរដ្ឋ និងស្រុក ថ្លៃផលប៉ះពាល់ និងការផ្ទេរប្រាក់ រួមទាំងពីវិធានការ Measure A

### មូលនិធិសេវាផ្ទៃក្នុង
### $607 លានដុល្លារ

ថវិកាទាំងនេះគិតគូរសម្រាប់សេវាផ្ទៃក្នុង ដែលផ្តល់ទៅឱ្យមន្ទីរក្រុងដោយគិតថ្លៃ ដល់នាយកដ្ឋានទាំងនោះសម្រាប់សេវាកម្ម។ រួមមាន មូលនិធិក្រុម និងមូលនិធិធានារ៉ាប់រង (Fleet and the Insurance Funds)។

## ការយល់ដឹងអំពីមូលនិធិទូទៅ

ជារៀងរាល់ឆ្នាំ មូលនិធិដែលមានសម្រាប់គាំទ្រសេវាកម្មទីក្រុងមានការប្រែប្រួល។ មូលនិធិទូទៅ ភាគច្រើនរួមមានចំណូលពន្ធ ហើយការចំណាយដ៏សំខាន់បំផុត គឺបុគ្គលិកដែលផ្តល់សេវាទីក្រុង។ លេខខាងក្រោមឆ្លុះបញ្ចាំងពីចំណែកប្រហាក់ប្រហែលនៃប្រភពចំណូល និងប្រភេទចំណាយនីមួយៗក្នុងមួយឆ្នាំ។

### ប្រភពចំណូល

| | |
|---|---|
| ពន្ធលើការលក់ & ការប្រើប្រាស់ (រួមទាំងវិធានការណ៍ Measure A) | 24% |
| ពន្ធលើអចលនទ្រព្យ | 24% |
| ការចោទប្រកាន់, ការផាកពិន័យ, និងការរឹបអូស | 12% |
| ពន្ធលើអចលនទ្រព្យ, ជំនួសថ្លៃអាជ្ញាប័ណ្ណយានយន្ត | 10% |
| អាជ្ញាប័ណ្ណ ការអនុញ្ញាត, & ថ្លៃសិទ្ធិធ្វើអាជីវកម្ម | 9% |
| ការផ្ទេរប្រាក់, សេវាអន្តរការី, & ចំណូលផ្សេងទៀត។ | 8% |
| ពន្ធផ្សេងៗ | 7% |
| ពន្ធអ្នកប្រើប្រាស់ទឹកភ្លើង/ឧបករណ៍ប្រើប្រាស់ | 6% |

### ការបំបែកខ្ទង់ចំណាយ

| | |
|---|---|
| ប្រាក់ខែ | 50% |
| ការចំណាយផ្សេងៗលើបុគ្គលិក | 26% |
| បរិក្ខារ & ការថែទាំ | 11% |
| កិច្ចសន្យា & សេវាកម្ម | 7% |
| ទឹកភ្លើង/ឧបករណ៍ប្រើប្រាស់, សម្ភារៈ, ផ្ទេរប្រាក់ | 6% |

**NOTES:**

**ចូលរួមក្នុងដំណើរការអភិវឌ្ឍថវិកាឆ្នាំសារពើពន្ធ FY 23:**

- ចូលរួមសវនាការនៅឯកិច្ចប្រជុំក្រុមប្រឹក្សាក្រុង
- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យថវិកា
- ចូលរួមកិច្ចប្រជុំសហគមន៍តាមអ៊ីនធឺណិត
- បំពេញកាតផ្តល់មតិយោបល់ថវិកាឌីជីថល

សម្រាប់ព័ត៌មានបន្ថែមអំពីថវិកា កិច្ចប្រជុំថវិការស្តីអំពីថវិការ និងនិងការស្ទង់មតិស្តីអំពីថវិកា មើលលើគេហទំព័រ **longbeach.gov/finance**


ទីក្រុងឡុងប៊ិច

411 W. Ocean Blvd.
Long Beach, Ca 90802

មើលលើគេហទំព័រ www.longbeach.gov

**@LongBeachCity**


ដើម្បីស្នើសុំព័ត៌មានជាទម្រង់ផ្សេងពីនេះ ឬស្នើសុំការសម្របសម្រួលសមស្របណាមួយ សូមទាក់ទងផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ តាមលេខ៖ 562.570.6225។ សូមដាក់សំណើយ៉ាងហោចណាស់បី(៣)ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីធានារៀបចំការសម្របសម្រួលនោះជូនទាន់។ សំណើដែលដាក់ខើចពេលជាងបីថ្ងៃនេះ ក៏យើងខ្ញុំនឹងប៉ុនប៉ងដោះស្រាយជូនទៅតាមការគួរ។